**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ៨៦/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# បទបង្ហាញជូនអង្គទូត
# ស្តីពីការវិវត្តថ្មីៗនៃស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ

នៅរសៀលថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម នង សាកល** អនុរដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានធ្វើបទបង្ហាញជូនតំណាងស្ថានបេសកកម្មការទូតទាំងអស់ និងអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ ប្រចាំកម្ពុជាដើម្បីផ្តល់ព័ត៌មានថ្មីៗអំពីការវិវត្តនៃស្ថានការណ៍នៅតាមព្រំដែនកម្ពុជា-ថៃ។

ក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអនុរដ្ឋលេខាធិការ** បានជម្រាបជូនអំពីលទ្ធផលនៃកិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។ ឯកឧត្តម បានគូសបញ្ជាក់ថា **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តឥតងាករេរបស់កម្ពុជា ចំពោះបទឈប់បាញ់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានកត់សម្គាល់ថា ទោះបីជាកម្ពុជាអនុវត្តការអត់ធ្មត់ជាអតិបរមា រួមទាំងការបដិសេធមិនឆ្លើយតបអស់រយៈពេលជាង ២៤ម៉ោងបន្ទាប់ពីការវាយប្រហារដំបូងកាលពីថ្ងៃទី៧ ខែធ្នូ ក៏ដោយ ក៏កម្ពុជានៅតែបន្តប្រឈមមុខនឹងការឈ្លានពានដោយយោធាថៃទាំងកំរោល។ ដើម្បីកាត់បន្ថយភាពតានតឹង **ឯកឧត្តម ប្រាក់ សុខុន** បានគូសបញ្ជាក់នៅកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅទីក្រុងគូឡាឡាំពួ ថា កម្ពុជាបានស្នើវិធានការជាក់ស្តែងចំនួនបី ដូចជា (១) **ការបញ្ឈប់ជាបន្ទាន់នូវអរិភាពទាំងអស់** និងការគោរពពេញលេញ ព្រមទាំងការអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ក៏ដូចជាកិច្ចព្រមព្រៀងផ្សេងៗទៀត ដែលសម្រេចបានក្នុងក្របខ័ណ្ឌនេះ **(២) ការសម្រួលកងកម្លាំងប្រដាប់អាវុធនៃប្រទេសទាំងពីរ** ត្រឡប់ទៅកាន់ទីតាំងដើមមុនការផ្ទុះឡើងនៃអរិភាព និងការវិលត្រឡប់ប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ដោយគ្មានការរាំងដល់ជនស៊ីវិលដែលរស់នៅក្នុងតំបន់ព្រំដែនដែលរងផលប៉ះពាល់ទៅកាន់លំនៅដ្ឋានរបស់ពួកគេវិញ និង (៣) **ការដោះស្រាយវិវាទ** រួមទាំងការបោះបង្គោលព្រំដែន តាមរយៈមធ្យោបាយសន្តិវិធីតែប៉ុណ្ណោះ ដោយអនុលោមតាមច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍(TAC) និងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់រវាងកម្ពុជានិងថៃ រួមទាំងការបន្តភ្លាមៗនូវការអនុវត្តពេញលេញនៃសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ទាក់ទងនឹងយន្តការទ្វេភាគី ឯកឧត្តម នង សាកល បានជម្រាបជូនអង្គទូតពីការរៀបចំកិច្ចប្រជុំក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការព្រំដែនទូទៅ (GBC) នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ នៅច្រកអន្តរជាតិព្រំ-បានប៉ាក់កាដ។ ឯកឧត្តមបានលើកឡើងថាកិច្ចប្រជុំនេះគឺជាជំហានដ៏សំខាន់មួយត្រៀមសម្រាប់កិច្ចប្រជុំពិសេស GBC លើកទី៣ ដែលគ្រោងធ្វើឡើងនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដោយមាន គោលបំណងចម្បងធានាឱ្យមានការបញ្ឈប់អរិភាព និងស្តារសន្តិភាពឡើងវិញ។ ឯកឧត្តមបានបញ្ជាក់ថា កម្ពុជា បានសង្កត់ធ្ងន់លើភាពចាំបាច់ ក្នុងការពង្រឹងតួនាទីរបស់ក្រុមអ្នកសង្កេតការណ៍អាស៊ាន( AOT ) ដើម្បីធានាការអនុវត្ត និងផ្ទៀងផ្ទាត់បទឈប់បាញ់ប្រកបដោយប្រសិទ្ធភាព។ ឯកឧត្តមក៏បានបង្ហាញក្តីសង្ឃឹមថានឹងទទួលបានលទ្ធផលវិជ្ជមានពីកិច្ចប្រជុំដ៏សំខាន់នេះ។

ពាក់ព័ន្ធនឹងការប្រឈមមុខដាក់គ្នាផ្នែកយោធាដែលកំពុងកើតឡើង ឯកឧត្តមអនុរដ្ឋលេខាធិការបានកត់សម្គាល់ថា ជម្លោះបានឈានចូលដល់ថ្ងៃទី១៩ហើយគិតចាប់តាំងពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥។ ឯកឧត្តមបានជម្រាបជូនអ្នកចូលរួមអំពីការវាយប្រហារកាន់តែខ្លាំងរបស់កងកម្លាំងប្រដាប់អាវុធថៃ ដោយប្រើប្រាស់សព្វាវុធបំផ្លិចបំផ្លាញខ្លាំង រួមមាន យន្តហោះចម្បាំង គ្រាប់បែកចង្កោម និងសារធាតុគីមីពុលចូលក្នុងទឹកដីកម្ពុជាចម្ងាយជាង១០០គីឡូម៉ែត្រ។ ឯកឧត្តមក៏បានលើកឡើងពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរ មកលើជនស៊ីវិល ដោយមានអ្នកស្លាប់ចំនួន ៣០នាក់ របួស៨៧នាក់ និងជនភៀសសឹកជាង ៦៣០ ០០០ នាក់ គិតត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥។ ឯកឧត្តមបានកត់សម្គាល់បន្ថែមលើការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរមកលើហេដ្ឋារចនាសម្ព័ន្ធ ទ្រព្យសម្បត្តិឯកជន អគារសាធារណៈ ប្រាសាទបុរាណ និងតំបន់បេតិកភណ្ឌពិភពលោក។ ឯកឧត្តម បានរំលឹកថា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC) បានថ្កោលទោសទង្វើទាំងនេះ ថាជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយ CHRC កំពុងរៀបចំការអំពាវនាវជាបន្ទាន់ទៅកាន់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីធានាឱ្យមានការទទួលខុសត្រូវពេញលេញតាមផ្លូវច្បាប់ចំពោះការរំលោភដ៏ធ្ងន់ធ្ងរទាំងនេះ។ ឯកឧត្តម ក៏បានបញ្ជាក់ផងដែរថា កម្ពុជានៅតែបន្តទាមទារឱ្យមានការដោះលែងកងទ័ពកម្ពុជាទាំង១៨នាក់ដែលកំពុងជាប់ឃុំឃាំងដោយគ្មានលក្ខខណ្ឌ។

ជុំវិញបញ្ហាមីន ឯកឧត្តមបានគូសបញ្ជាក់ថា ប្រទេសថៃបាននិងកំពុងមានចេតនាកេងចំណេញលើបញ្ហាមីននេះ តាមរយៈរូបភាពដែលមិនមានការផ្ទៀងផ្ទាត់ត្រឹមត្រូវ ការបង្កើតឈុតឆាក និងនិទានកថាជាឯកតោភាគីដោយយោធាថៃ ក៏ដូចជាការបិទបាំងនយោបាយ ដើម្បីបង្វែរចំណាប់អារម្មណ៍លើការប្រើប្រាស់កម្លាំងអាកាសរបស់ខ្លួនប្រឆាំងជនស៊ីវិល និងបង្វែរការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិពីការឈ្លានពានទឹកដីកម្ពុជា។

ជាចុងបញ្ចប់ ឯកឧត្តម នង សាកល បានគូសបញ្ជាក់ថា កម្ពុជានៅតែប្តេជ្ញាយ៉ាងមុតមាំ និងខ្ជាប់ខ្ជួនចំពោះបទឈប់បាញ់ជាបន្ទាន់ និងចំពោះការរក្សាសន្តិភាព និងស្ថិរភាព ព្រមទាំងការអនុវត្តការអត់ធ្មត់ជាអតិបរមា និងបន្តផ្តល់អាទិភាពលើកិច្ចសន្ទនា ការទូត និងដំណោះស្រាយការប្រឈម និងជម្លោះ ដោយសន្តិវិធី៕

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥